ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍

ទេសចរណ៍សៀមរាប-អង្គរ

លេខ: ០០១.សសរ.គអទស

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## ប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- បានឃើញអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

### ប្រការ១ .-

សេចក្តីសម្រេចនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដែលសរសេរជាអក្សរកាត់ថា លេខាធិការដ្ឋាន **គ.អ.ទ.ស.**។

### ប្រការ២ .-

លេខាធិការដ្ឋាន **គ.អ.ទ.ស.** មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- សម្របសម្រួលចាត់ចែងអនុវត្តរាល់សកម្មភាពការងារប្រចាំថ្ងៃរបស់ **គ.អ.ទ.ស.**

- សិក្សាស្រាវជ្រាវអំពីសក្តានុពលធនធានទេសចរណ៍ ដែលមានក្នុងតំបន់សៀមរាប-អង្គរ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដានលើការធ្វើអាជីវកម្មក្នុងតំបន់សៀមរាប-អង្គរ
- ប្រមូលទិន្នន័យនិងធ្វើការវិភាគនូវរាល់ព័ត៌មាននិងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ ចំពោះមុខ និងយូរអង្វែង ក្នុងការកំណត់ទីតាំងគោលដៅបម្រើដល់កិច្ចអភិវឌ្ឍន៍និងអភិរក្ស
- ពិនិត្យ តាមដាន និងផ្តល់យោបល់លើគម្រោងវិនិយោគសាធារណៈ និងឯកជនបម្រើឱ្យការអភិវឌ្ឍវិស័យទេសចរណ៍សៀមរាប-អង្គរ ជូន **គ.អ.ឱ.ស.**
- សហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្សនិងអភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់សៀមរាប-អង្គរ
- រៀបចំគោលនយោបាយ ទស្សនវិស័យ និងបេសកកម្មរបស់ **គ.អ.ឱ.ស.**
- សម្របសម្រួលនិងសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ប្រកបដោយនិរន្តរភាព
- សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធអនុវត្តគម្រោង និងជំរុញការវិនិយោគក្នុងវិស័យទេសចរណ៍ក្នុងតំបន់សៀមរាប-អង្គរ
- សម្របសម្រួលការងារនានារបស់អង្គភាពចំណុះរបស់ **គ.អ.ឱ.ស.**
- រៀបចំចងក្រងឯកសារទិន្នន័យនិងព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- រៀបចំកិច្ចប្រជុំនិងសិក្ខាសាលានានារបស់ **គ.អ.ឱ.ស.**
- រៀបចំរបាយការណ៍ជាប្រចាំ ជូនប្រធាន **គ.អ.ឱ.ស.**
- អនុវត្តការកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.អ.ឱ.ស.**។

**ប្រការ៣ ._**

លេខាធិការដ្ឋាន **គ.អ.ឱ.ស.** មានរចនាសម្ព័ន្ធ ដូចខាងក្រោម៖

- ផ្នែកផែនការអភិវឌ្ឍន៍ បណ្តុះបណ្តាល និងនីតិកម្ម
- ផ្នែកសហប្រតិបត្តិការ និងទំនាក់ទំនងសាធារណៈ
- ផ្នែករដ្ឋបាលនិងកិច្ចការទូទៅ។

ផ្នែកនីមួយៗ ដឹកនាំដោយប្រធាន១រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់ផ្នែកនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ឱ.ស.**។

ផ្នែកនីមួយៗ អាចមានការិយាល័យចំណុះមួយចំនួន តាមការចាំបាច់។ អង្គការលេខនៃរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន **គ.អ.ឱ.ស.** ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ ៤._**

ផ្នែកផែនការអភិវឌ្ឍន៍ បណ្តុះបណ្តាល និងនីតិកម្ម មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- ប្រមូល រៀបចំ គ្រប់គ្រង និងវិភាគទិន្នន័យលទ្ធផលការងារ ដែលទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធ ដើម្បីកំណត់ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ កម្មវិធីនិងផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែងបម្រើដល់ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ស្របតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥
- សហការជំរុញការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍នៅតាមគោលដៅនានាក្នុងខេត្តសៀមរាប
- តាមដាននិងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាព
- សហការរៀបចំនិងវាយតម្លៃអំពីតម្រូវការសម្រាប់ការបណ្តុះបណ្តាលនិងការអភិវឌ្ឍធនធានមនុស្សក្នុង

លេខាធិការដ្ឋាន **គ.អ.ទ.ស**. និងគ្រប់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

- សហការរៀបចំកម្មវិធីបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់មន្ត្រីលេខាធិការដ្ឋាន **គ.អ.ទ.ស**. និងគ្រប់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- រៀបចំ អង្កេត និងវាយតម្លៃការអនុវត្តផែនការនិងគម្រោងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- រៀបចំកសាងឯកសារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍សៀមរាប-អង្គរ ដោយសហការជាមួយអង្គភាពនិងក្រសួង ស្ថាប័នពាក់ព័ន្ធ
- អនុវត្តកិច្ចការងារសម្រាប់លេខាធិការដ្ឋាន **គ.អ.ទ.ស**. ដែលពាក់ព័ន្ធនឹងការងារឌីជីថល
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារជូនប្រធានលេខាធិការដ្ឋាន **គ.អ.ទ.ស**.
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.អ.ទ.ស**.។

**ប្រការ៥ .—**

ផ្នែកសហប្រតិបត្តិការ និងទំនាក់ទំនងសាធារណៈ មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- រៀបចំគម្រោងសហប្រតិបត្តិការជាមួយអង្គការ សមាគមជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ជាតិនិងអន្តរជាតិ លើរាល់សកម្មភាពដែលទាក់ទងនឹងការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍សៀមរាប-អង្គរ
- ពិនិត្យ តាមដាន វាយតម្លៃ និងផ្តល់យោបល់លើរាល់គម្រោងវិនិយោគនានាបម្រើឱ្យការអភិវឌ្ឍវិស័យទេសចរណ៍សៀមរាប-អង្គរ និងគ្រប់សកម្មភាពដែលមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀង ជូនថ្នាក់ដឹកនាំពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហការក្នុងក្របខ័ណ្ឌការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍សៀមរាប-អង្គរ
- សម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- សហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ដើម្បីកៀគរកជំនួយ
- ជំរុញការចូលរួមពីសាធារណជន និងគ្រប់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍទេសចរណ៍សៀមរាប-អង្គរ
- ផ្សព្វផ្សាយព័ត៌មាន សំដៅបម្រើឱ្យការងារគ្រប់គ្រង និងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព
- ប្រមូល រៀបចំ គ្រប់គ្រង និងវិភាគទិន្នន័យលទ្ធផលការងារ ដែលទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធដើម្បីកំណត់ និងរៀបចំបញ្ជីសក្តានុពលវិនិយោគទេសចរណ៍ និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិពាក់ព័ន្ធនឹងគម្រោងវិនិយោគ ស្របតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារជូនប្រធានលេខាធិការដ្ឋាន **គ.អ.ទ.ស**.
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.អ.ទ.ស**.។

**ប្រការ៦ .—**

ផ្នែករដ្ឋបាលនិងកិច្ចការទូទៅ មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- ទទួលខុសត្រូវលើសេវាកម្មរដ្ឋបាលទូទៅនិងសម្របសម្រួលការងាររដ្ឋបាល ជូនគ្រប់អង្គភាពនៅក្រោមឱវាទលេខាធិការដ្ឋាន **គ.អ.ទ.ស**.
- ទទួលខុសត្រូវលើការងារគ្រប់គ្រង ចាត់ចែង និងចរាចរឯកសាររដ្ឋបាលរបស់ **គ.អ.ទ.ស**.
- ធានាប្រសិទ្ធភាព សុវត្ថិភាព និងគ្រប់គ្រងការងាររដ្ឋបាល
- ទទួលបន្ទុកក្នុងការរៀបចំសន្និបាត សិក្ខាសាលា កិច្ចប្រជុំ និងពិធីការនានា ព្រមទាំងធ្វើរបាយការណ៍និងកំណត់ហេតុប្រជុំ
- លើកគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.អ.ទ.ស**.
- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកក្នុងលេខាធិការដ្ឋាន **គ.អ.ទ.ស**.

- បូកសរុបនិងរៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់លេខាធិការដ្ឋាន **គ.អ.ទ.ស**.
- រៀបចំគម្រោងផែនការសម្ភារៈនិងមធ្យោបាយនានារបស់លេខាធិការដ្ឋាន **គ.អ.ទ.ស**.
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារជូនប្រធានលេខាធិការដ្ឋាន **គ.អ.ទ.ស**.
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.អ.ទ.ស**.។

**ប្រការ៧ .‒**

លេខាធិការដ្ឋាន **គ.អ.ទ.ស**. អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនឱ្យចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

**ប្រការ៨ .‒**

លេខាធិការដ្ឋាន **គ.អ.ទ.ស**.អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិនិងអន្តរជាតិ និងមន្ត្រីជាប់កិច្ចសន្យា ដើម្បីបំពេញការងាររបស់ខ្លួន តាមការចាំបាច់។

**ប្រការ៩ .‒**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .‒**

អនុប្រធាន សមាជិក និងប្រធានគ្រប់អង្គភាពចំណុះ **គ.អ.ទ.ស**. ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១៥កើត ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ សីហា ឆ្នាំ២០២៤

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន**
**គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

**ថោង ខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងទេសចរណ៍
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តសៀមរាប
- ដូចប្រការ១០
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ០០១.សសរ.គអរទស.ចុះថ្ងៃទី១៩...ខែ.សីហា.ឆ្នាំ២០២៤**

**ស្ដីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន**

**នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន**

**នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

